## ការលើកលែងពីការប្រើប្រាស់ថ្នាំសម្លាប់សត្វល្អិតនៅតំបន់ធំទូលាយ
## សំណួរដែលសាកសួរញឹកញាប់

**1. តើខ្ញុំត្រូវទទួលបានការលើកលែងពីការបាញ់នៅបរិវេណរបស់ខ្ញុំដោយរបៀបណា?**
សំណើលើកលែងអាចដាក់ជូនពិនិត្យនៅនាយកដ្ឋានធនធានកសិកម្មនៃរដ្ឋម៉ាសាជូសេត (Massachusetts Department of Agricultural Resources, MDAR) នៅពេលណាមួយនៅអំឡុងឆ្នាំនេះ តាមសេវាប្រៃសណីយ៍ថ្នាក់ទីមួយ ឬតាមទម្រង់អនឡាញ។ ចំណុចទាំងអស់ត្រូវបំពេញទាំងស្រុងដោយម្ចាស់បរិវេណ ឬអ្នកជួលផ្ទះ។ ប្រសិនបើដាក់ជូនពិនិត្យសំណើឯកសារជាក្រដាសនោះ ត្រូវតែផ្ញើតាមសេវាប្រៃសណីយ៍ថ្នាក់ទីមួយ ដោយប្រើទម្រង់ដែលអាចមាននៅលើគេហទំព័ររបស់នាយកដ្ឋានធនធានកសិកម្ម MDAR។ នៅពេលដែលសំណើបានទទួលដោយនាយកដ្ឋាន MDAR នោះ បន្ទាប់មកសំណើនេះនឹងត្រូវផ្ទេរទៅគម្រោង/មណ្ឌលគ្រប់គ្រងមូស (Mosquito Control District/Project) ដែលមាននៅតំបន់នេះ ដែលបរិវេណនោះស្ថិតនៅ ប្រសិនបើអាចអនុវត្តបាន។ បរិវេណនានាដែលត្រូវលើកលែង នឹងត្រូវបញ្ចូលទៅក្នុងមូលដ្ឋានទិន្នន័យដែលរៀបចំឡើង ដើម្បីតាមដានបរិវេណដែលលើកលែង ដែលគម្រោងនឹងប្រើនៅអំឡុងពេលការប្រើប្រាស់តំបន់ធំទូលាយ។

**2. តើសំណើរបស់ខ្ញុំចូលជាធរមានរយៈពេលប៉ុន្មាន ហើយនៅពេលណាដែលសំណើផុតកំណត់?**
សំណើលើកលែងចូលជាធរមានក្នុងរយៈពេល 14 ថ្ងៃ ដោយគិតចាប់ពីថ្ងៃដែលសំណើត្រូវបានបង្កើតឡើង និងផុតកំណត់នៅថ្ងៃទី 31 ខែធ្នូ នៃឆ្នាំប្រតិទិនដែលក្នុងនោះ បានទទួលសំណើ។

**3. តើការណ៍នេះជាការលើកលែងខ្ញុំពីការប្រើប្រាស់ថ្នាំសម្លាប់សត្វល្អិតទាំងអស់ឬទេ?**
បទប្បញ្ញត្តិនេះ ទាក់ទងតែការប្រើប្រាស់ "តំបន់ធំទូលាយ" ប៉ុណ្ណោះ។ ការប្រើប្រាស់ "តំបន់ធំទូលាយ" គឺជាការប្រើប្រាស់ថ្នាំសម្លាប់សត្វល្អិតដែលធ្វើឡើងលើផ្ទៃដីមួយហិចតា ឬច្រើនជាងនេះ ឬនៅទូទាំងព្រំប្រទល់បរិវេណ។ នៅរដ្ឋ Massachusetts ការប្រើប្រាស់ "តំបន់ធំទូលាយ" ជាច្រើនទាក់ទងនឹងកម្មវិធីគ្រប់គ្រងមូស ដែលធ្វើឡើងដោយគម្រោង/មណ្ឌលគ្រប់គ្រងមូស (Mosquito Control District/Project) ផ្សេងៗ។

បទប្បញ្ញត្តិនេះ មិនទាក់ទងនឹងបុគ្គលដែលជួលក្រុមហ៊ុនសម្រាប់គោលបំណងគ្រប់គ្រងមូស ឬគោលបំណងគ្រប់គ្រងសត្វល្អិតផ្សេងទៀតទេ ដោយសារការប្រើប្រាស់ទាំងនោះត្រូវកំណត់ជាក់លាក់ចំពោះបរិវេណរបស់អង្គភាពចុះកិច្ចសន្យា។

**4. តើអ្វីជាដំណើរការប្រើប្រាស់ថ្នាំសម្លាប់ដង្កូវ (Larviciding) និងដំណើរការប្រើប្រាស់ថ្នាំសម្លាប់មូសពេញវ័យ (Adultticiding)?**
**Larviciding** គឺជាវិធីសាស្ត្រគ្រប់គ្រងគីមីដែលគ្រប់គ្រងមូសតាមទម្រង់ដង្កូវរបស់វា ជាដំណាក់កាលងាយរងគ្រោះបំផុតរបស់វា។ ដោយសារដង្កូវមូស ត្រូវបង្ខាំងនៅក្នុងបរិស្ថានក្នុងទឹក ដែលការប្រើប្រាស់ថ្នាំសម្លាប់ដង្កូវតាមគោលដៅអាចប្រើ ដើម្បីការពារមូសពីការក្លាយជាមូសពេញវ័យ។ ថ្នាំសម្លាប់ដង្កូវអាចប្រើប្រាស់ទៅលើទឹកដែលកខ្វក់នៅតំបន់ដីសើម អាងចិញ្ចឹមត្រី និងធុងផ្ទុកទឹក ដើម្បីគ្រប់គ្រងមូសក្នុងដំណាក់កាលដង្កូវមិនទាន់ពេញវ័យ។ Larviciding គឺជាជម្រើសត្រួតពិនិត្យដែលពេញចិត្តពីព្រោះថ្នាំសម្លាប់ដង្កូវអាចកាត់បន្ថយតម្រូវការថ្នាំសម្លាប់មូសពេញវ័យនៅពេលក្រោយមកទៀត។ ថ្នាំសម្លាប់ដង្កូវទូទៅបំផុតដែលប្រើប្រាស់មានផ្ទុកនូវថ្នាំសម្លាប់សត្វល្អិត "ជីវសាស្ត្រ" ដូចជា Bt.k. ដែលសារធាតុសកម្មគឺ *Bacillus thuringiensis kurstaki* ដែលជាបាក់តេរីដែលកំណត់គោលដៅមូសដោយវាយប្រហារពោះវៀនដង្កូវ។ តាមធម្មតាផលិតផលទាំងនេះត្រូវបានអនុវត្តដោយដៃនៅក្នុងតំបន់តូចៗ ឬដោយឧបករណ៍ប្រើពីលើអាកាស ដូចជាយន្តហោះខ្នាតតូច និងឧទ្ធម្ភាគចក្រ ដើម្បីផ្តល់ជូនការគ្របដណ្តប់ដូចគ្នាទាំងអស់នៅលើតំបន់ធំ។

**Adultticiding** គឺជាវិធីសាស្ត្រគ្រប់គ្រងសារធាតុគីមីដែលប្រើប្រាស់ដើម្បីគ្រប់គ្រងមូសនៅដង់ស៊ីតេមូសខ្ពស់ ឬដើម្បីទប់ស្កាត់ការគំរាមកំហែងពីជំងឺឆ្លងពីមូស (វីរុសដែលឆ្លងតាមសត្វល្អិតខាំ (arbovirus) )។ វិធីសាស្ត្រនេះ អាចពាក់ព័ន្ធនឹងការប្រើប្រាស់ឧបករណ៍ដែលបំពាក់ដោយរថយន្តដែលមានឯកទេសខ្ពស់ ដើម្បីកំណត់គោលដៅព្យាបាលទៅកាន់តំបន់ដែលបានជ្រើសរើស។ ប្រសិនបើមានការធានាជាពិសេសក្នុងករណីមានអាសន្នផ្នែកសុខភាពសាធារណៈនោះ ការអនុវត្តពីលើអាកាសអាចនឹងត្រូវបានប្រើប្រាស់ដើម្បីគ្របដណ្តប់តំបន់ទូលំទូលាយ។

**5. តើអ្នកណាអាចដាក់ពាក្យសុំការលើកលែងនេះ?**
មានតែម្ចាស់ផ្ទះជួល ឬអ្នកជួលផ្ទះប៉ុណ្ណោះ ដែលអាចដាក់ពាក្យសុំការលើកលែងពីការប្រើប្រាស់ថ្នាំសម្លាប់សត្វល្អិតលើបរិវេណរបស់ពួកគេ។
ប្រសិនបើសំណើនេះ ត្រូវបានធ្វើឡើងដោយអ្នកជួលផ្ទះនោះ ឈ្មោះ និងព័ត៌មានទំនាក់ទំនងសម្រាប់ម្ចាស់ផ្ទះជួល ក៏ត្រូវផ្តល់ជូនផងដែរ។

**6. តើវិធីសាស្ត្រសម្គាល់ដែលបានអនុម័តមានអ្វីខ្លះ ហើយតើខ្ញុំគួរដាក់នៅកន្លែងណា?**
ព្រំប្រទល់នៃបរិវេណដែលបានលើកលែងនោះ តែត្រូវកត់សម្គាល់ដោយចានប្លាស្ទិកពណ៌ស ឬចានអាលុយមីញ៉ូមដែលមានអង្កត់ផ្ចិតយ៉ាងតិច 9 អ៊ីញ ដែលមានពាក្យថា "ហាមបាញ់ថ្នាំ" ("No Spray") ដែលសរសេរយ៉ាងច្បាស់នៅក្នុងសញ្ញាសម្គាល់អចិន្ត្រៃយ៍។
ចាននានាត្រូវតែដាក់នៅលើដើមឈើ ស្ទឹង ឬបង្គោលដែលអាចមើលឃើញយ៉ាងងាយពីផ្លូវ យ៉ាងហោចណាស់រៀងរាល់ 50 ហ្វីត តាមបណ្តោយព្រំប្រទល់នៃបរិវេណដែលនៅជាប់នឹងផ្លូវ និងមិនលើសពី 5 ហ្វីតពីផ្លូវ។

**7. តើមានអ្វីកើតឡើងចំពោះសំណើការលើកលែងរបស់ខ្ញុំនៅអំឡុងពេលមានអាសន្នសុខភាពសាធារណៈ?**
ក្នុងករណីមានស្ថានភាពបន្ទាន់ដែលតម្រូវឱ្យមានការប្រើប្រាស់ថ្នាំសម្លាប់សត្វល្អិតជាបន្ទាន់តាមយន្តហោះនោះ នាយកដ្ឋានធនធានកសិកម្ម MDAR អាចបដិសេធ ឬកែប្រែបទប្បញ្ញត្តិណាមួយឬទាំងអស់នេះ ដោយអនុលោមតាម 333 CMR 13.04។

**8. តើខ្ញុំដឹងតាមរបៀបណាថាទីក្រុងរបស់ខ្ញុំ ស្ថិតនៅក្នុងមណ្ឌលមួយ?**
លោកអ្នកអាចចូលមើលគេហទំព័ររបស់យើង ដើម្បីមើលថាតើទីក្រុងរបស់អ្នកគឺជាផ្នែកមួយនៃមណ្ឌលមួយឬទេ៖
http://www.mass.gov/eea/agencies/agr/pesticides/mosquito/
http://www.mass.gov/eea/agencies/agr/pesticides/mosquito/mosquito-control-projects-and-districts.html

**9. តើខ្ញុំត្រូវស្វែងរកព័ត៌មានទំនាក់ទំនងមណ្ឌលរបស់ខ្ញុំដោយរបៀបណា?**
**ហើយតើខ្ញុំត្រូវទាក់ទងអ្នកណានៅពេលមានសំណួរទាក់ទងនឹងការប្រើប្រាស់ថ្នាំសម្លាប់សត្វល្អិត ឬការងារផ្សេងទៀតដែលមណ្ឌលអនុវត្ត?**
ចំណុចខាងក្រោមនេះ គឺជាបញ្ជីនៃមណ្ឌលគ្រប់គ្រងមូសទាំងអស់នៅសហគមន៍ទូទៅ
ដែលបញ្ជីនេះតែងតែអាចមានដើម្បីឆ្លើយសំណួរទាក់ទងនឹងការប្រើប្រាស់ថ្នាំសម្លាប់សត្វល្អិត និងគម្រោងផ្សេងទៀតដែលពួកគេកំពុងធ្វើការ។

**A. គម្រោងគ្រប់គ្រងមូសខោនធីប័កសៀ (Berkshire County Mosquito Control Project)**
19 Harris Street, Pittsfield, MA 01201 ទូរស័ព្ទ៖ 413-447-9808 ទូរសារ៖ 413- 447-7185
berkmc@bcn.net

**B. គម្រោងគ្រប់គ្រងមូសខោនធីប្រីស្តូន (Bristol County Mosquito Control Project)**
38R Forest Street, Attleboro, MA 02703 ទូរស័ព្ទ៖ 508-823-5253 ទូរសារ៖ 508-828-1868 Priscilla.Matton@massmail.state.ma.us

**C. គម្រោងគ្រប់គ្រងមូសខោនធីខេប កូដ (Cape Cod Mosquito Control Project)**
259 Willow Street, 2nd floor, Yarmouth Port, MA 02675 ទូរស័ព្ទ៖ 508-775-1510

**D. គម្រោងគ្រប់គ្រងមូសខោនធីរដ្ឋម៉ាសាជូសេតភាគកណ្តាល (Central Massachusetts Mosquito Control Project)**
111 Otis Street, Northborough, MA 01532 ទូរស័ព្ទ៖ 508-393-3055 ទូរសារ៖ 508-393-8492 cmmcp@cmmcp.org

**E. គម្រោងគ្រប់គ្រងមូសខោនធីអ៊ីសមីតដលស៊ិច (East Middlesex Mosquito Control Project)**
11 Sun Street, Waltham, MA 02453 ទូរស័ព្ទ៖ 781-899-5730 ទូរសារ៖ 781-647-4988

emmcp.dh@verizon.net

**F. មណ្ឌលគ្រប់គ្រងមូសខោនធីណតហ្វ័ក (Norfolk County Mosquito Control District)**
61 Endicott Street, Suite 66, Norwood, MA 02062 ទូរស័ព្ទ៖ 781-762-3681 ទូរសារ៖ 781-769-6436 info@norfolkcountymosquito.org

**G. មណ្ឌលគ្រប់គ្រងមូស និងតំបន់ដីសើមខោនធីណតអ៊ីស មេស (Northeast Mass. Mosquito & Wetlands Management Distric)**
118 Tenney Street, Georgetown, MA 01833 ទូរស័ព្ទ៖ (978) 352-2800 nemmc@comcast.net

**H. មណ្ឌលគ្រប់គ្រងមូសខោនធីព្យូននៀ វ៉ាឡី (Pioneer Valley Mosquito Control District)**
ទូរស័ព្ទ៖ 401-580-6397 John.C.Briggs@mass.gov

**I. គម្រោងគ្រប់គ្រងមូសខោនធីភ្លីម៉ូត (Plymouth County Mosquito Control Project)**
142R Pembroke Street, PO Box 72, Kingston, MA 02364 ទូរស័ព្ទ៖ 781-585-5450 ទូរសារ៖ 781-582-1276
Denise.Deluca@state.ma.us

**J. គម្រោងគ្រប់គ្រងមូស (Suffolk County Mosquito Control Project )**
11 Sun Street, Waltham, MA 02453 781-899-5730 ទូរសារ៖ 781-647-4988
emmcp.dh@verizon.net